00612846

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D424/3/2

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ១០៥)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 10 / 2010
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នំយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០

---

**សាធារណៈ**

# សេចក្ដីសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រ សម្រាប់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តសៀមរាប

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
អៀង ធីរិទ្ធ
អៀង សារី
នួន ជា
ខៀវ សំផន

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី

**សហមេធាវីការពារក្ដីជនត្រូវចោទ**
អៀង ធីរិទ្ធ
ផាត់ ពៅសៀង

នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Elizabeth RABESANRATANA
Olivier BAHOUGNE
ស៊ិន សុវ៉ន
ជេត វណ្ណលី
ពេជ អង្គ
Lyma NGUYEN
វ៉េន ពៅ
Annie DELAHAIE
Mahdev MOHAN
Marie GUIRAUD
Patrick BAUDOIN
Fabienne TRUSSES-NAPROUS
Ferdinand DJAMMEN-NZEPA
Christine MARTINEAU
Laure DESFORGES
Isabelle DURAND
Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Daniel LOSQ
Julien RIVET
Pascal AUBOIN
Francoise GAUTRY

Diana ELLIS

អៀង សារី
អាង ឧត្តម
Michael G. KARNAVAS

នួន ជា
សុន អរុណ
Michel PESTMAN
Victor KOPPE

ខៀវ សំផន
ស សុវាន
Jacques VERGES
Philippe GRECIANO

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួល “សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តសៀមរាប”(“សំណើសុំ”) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០។ អង្គបុរេជំនុំជម្រះ ក៏បានទទួលបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំពីខេត្តសៀមរាប (“បណ្តឹងឧទ្ធរណ៍”) ដែលបានដាក់នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ដែលបណ្តឹងឧទ្ធរណ៍នេះ មានចំនួនទំព័រលើសពីចំនួនទំព័រដែលបានកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ និងបានទទួលការជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ ដែលបានដាក់ជូនក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០[១]។

១. ជាបឋម អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ខ្លួនមិនបានទទួលសំណើនេះត្រឹមត្រូវតាមនីតិវិធី មុនពេលវេលាកំណត់នៃការដាក់បណ្តឹងឧទ្ធរណ៍ទេ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមនេះ មិនបានបំពេញតាមលក្ខខណ្ឌស្តីពីការដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ជូនក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដែលតម្រូវដោយវិធាន ៧៧(១) នៃវិធានផ្ទៃក្នុង ឲ្យបានមុនការដាក់សំណើ និងឲ្យបានមុនការដាក់បណ្តឹងឧទ្ធរណ៍នោះទេ។ ជាងនេះទៀត សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេល ១០ ថ្ងៃ ដែលជាពេលវេលាអនុញ្ញាតឲ្យដាក់សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ និងការដាក់បណ្តឹងឧទ្ធរណ៍ ស្របតាមវិធាន ៧៧(១) និងវិធាន ៧៧*ស្ទួន*[២] នៃវិធានផ្ទៃក្នុងឡើយ។ វាគឺជាការចាំបាច់ដែលថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ មុនពេលដែលខ្លួនដាក់បណ្តឹងឧទ្ធរណ៍ និងមុនពេលដែលខ្លួនដាក់សំណើសុំបន្ថែមចំនួនទំព័រ សម្រាប់បណ្តឹងឧទ្ធរណ៍ដូចនេះ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានទទួលការណែនាំច្រើនដងរួច

---

[១] សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D424/3។

[២] ដីកា ត្រូវបានដាក់នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០។ ដូចនេះ សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ត្រូវតែបានដាក់មិនឲ្យហួសថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១០ នោះទេ។



PRE-TRIAL CHAMBER E.C.C.C * C.E.T.C CHAMBRE PRELIMINAIRE

ហើយថា មេធាវីត្រូវតែដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ មុននឹងដាក់បណ្ដឹងឧទ្ធរណ៍ ឬសំណើ ដែលពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីការទទួលយកពាក្យសុំ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដោយសារមាននីតិវិធីបណ្ដឹងឧទ្ធរណ៍សង្ខេបតាមវិធាន៧៧*ស្ទួន* ចៅក្រម និងក្រឡាបញ្ជីអង្គបុរេជំនុំជម្រះបានខិតខំប្រឹងប្រែងអស់លទ្ធភាព ក្នុងការពិនិត្យពិចារណាលើសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឱ្យបានលឿន ដោយរួមទាំងការឆ្លើយតបទៅនឹងសំណើតាមអ៊ីមែល ដើម្បីជួយឱ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលសេចក្ដីជូនដំណឹងទាន់ពេលវេលា ស្ដីពីសេចក្ដីសម្រេច ដោយសេចក្ដីសម្រេច នេះអាចមានផលប៉ះពាល់ដល់ការរៀបចំបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានរៀបចំក្នុងនាមអ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ការអនុវត្តបែបនេះមិនផ្លាស់ប្ដូរលក្ខខណ្ឌដែលចែងថា ដំបូងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ជូនក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ហើយការដាក់សេចក្ដីជូនដំណឹងនេះ ត្រូវធ្វើឡើងមុនពេលវេលាកំណត់ ដែលអនុញ្ញាតសម្រាប់ការដាក់បណ្ដឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះ សូមបញ្ជាក់សារជាថ្មីថា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានកាតព្វកិច្ចគោរពតាមនីតិវិធី ដែលអនុវត្តចំពោះមុខ អ.វ.ត.ក ជាពិសេស ត្រូវគោរពតាមលក្ខខណ្ឌស្ដីពីការជូនដំណឹងពីការដាក់បណ្ដឹងឧទ្ធរណ៍ ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុង។ បើទោះបីជា សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានបំពេញតាមលក្ខខណ្ឌ បើទោះបីជាខ្លួនបានទទួលការជូនដំណឹងអំពីលក្ខខណ្ឌទាំងនេះពីអង្គបុរេជំនុំជម្រះនៅមុនការកន្លងផុតទៅនៃកាលបរិច្ឆេទកំណត់សម្រាប់ការដាក់បណ្ដឹងឧទ្ធរណ៍ក៏ដោយ[៣] ក៏អង្គបុរេជំនុំជម្រះនឹងមិនពិន័យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹង រដ្ឋប្បវេណីម្នាក់ៗ ដោយសារតែការមិនគោរពតាមនីតិវិធីរបស់មេធាវីនោះទេ។

---

[៣] នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ បានជូនដំណឹងដល់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈអ៊ីមែលថា សំណើសុំបន្ថែមចំនួនទំព័រ មិនអាចយកមកពិចារណាបានឡើយ ហើយការពិចារណានឹងធ្វើបន្ទាប់ពី សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សេចក្ដីជូនដំណឹងពីការដាក់បណ្ដឹងឧទ្ធរណ៍ជូនក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត។ សូមមើលអ៊ីមែល ដែលបានផ្ញើពី Sarah CLANTON ជូន លោកស្រី ជេត វណ្ណលី

២. ក្នុងសំណើរបស់ខ្លួន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើឱ្យអង្គបុរេជំនុំជម្រះ ៖

១) អនុវត្តឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតឱ្យបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ ដល់ចំនួន ១២០ទំព័រ ជាភាសាខ្មែរ ដោយមិនរាប់បញ្ចូលទំព័រចំណងជើង ទំព័រឯកសារយោង និងទំព័រឧបសម្ព័ន្ធ ដើម្បីឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធនឹងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០៨នាក់។

២) ផ្តល់ការឆ្លើយតបទៅនឹងសំណើនេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យឆ្លើយតបទៅនឹងតាមភាពបន្ទាន់នៃបណ្តឹងឧទ្ធរណ៍សង្ខេប។

៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើសុំបន្ថែមចំនួនទំព័ររបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងក្នុងកាលៈទេសៈពិសេស ដូចខាងក្រោមនេះ៖ ១) បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធនឹងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានចំនួនច្រើន (១០៨នាក់) ២) ការកំណត់បណ្តឹងឧទ្ធរណ៍ឱ្យមានចំនួនត្រឹមតែ ៣០ទំព័រ អាចនឹងបណ្តាលឱ្យមានភាពអយុត្តិធម៌ចំពោះអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារការកំហិតបែបនេះអាចឱ្យអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីកាត់ចោលខ្លឹមសារ ស្តីពីអង្គហេតុ និងអង្គច្បាប់មួយចំនួនធំ ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ និង ៣) ការកំណត់នេះ នឹងលែងនាំឱ្យមានការព្រួយបារម្ភពាក់ព័ន្ធនឹងការគ្រប់គ្រងឯកសារ និងការពិនិត្យបណ្តឹងឧទ្ធរណ៍ទៀតហើយ ពីព្រោះវានឹងមានការបើកសវនាការលើបណ្តឹងតែមួយ និង

---

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០។ គោលជំហរនេះ ត្រូវបានបញ្ជាក់បន្ថែម តាមរយៈទំនាក់ទំនងតាមទូរស័ព្ទរវាង ឈន ព្រលឹង និងជេត វណ្ណលី នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០។ ជាចុងក្រោយ ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះបានផ្តល់ព័ត៌មានដល់លោកស្រី ជេត វណ្ណលី តាមរយៈអ៊ីមែល នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ថា ទោះបីការពិតថា ពេលនោះវាជាថ្ងៃចុងក្រោយសម្រាប់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ក្តី អង្គបុរេជំនុំជម្រះតម្រូវឱ្យភាគីទាំងអស់គោរពតាមវិធានផ្ទៃក្នុង រួមទាំងការដាក់សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍មុនពេលអង្គបុរេជំនុំជម្រះពិចារណាលើសំណើសុំបន្ថែមចំនួនទំព័រ។ សូមមើលអ៊ីមែលរបស់ ឈន ព្រលឹង ផ្ញើជូនជេត វណ្ណលី នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០។



E.C.C.C * C.E.T.C
TRIAL CHAMBER CHAMBRE PRELIMINAIRE

មិនមែនជាការតម្រូវឱ្យអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ដាក់បណ្តឹងឧទ្ធរណ៍រៀងៗខ្លួននោះទេ។

៤. អង្គបុរេជំនុំជម្រះពិចារណាឃើញថា មូលហេតុ ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងស្តីអំពីការសុំបន្ថែមចំនួនទំព័រ ពិតជាបង្ហាញច្បាស់លាស់អំពីកាលៈទេសៈពិសេស តាមអត្ថន័យនៃបទប្បញ្ញត្តិក្នុងមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្ត។

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ ÷

**សម្រេច** អនុញ្ញាតឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមចំនួនទំព័របណ្តឹងឧទ្ធរណ៍តាមការស្នើសុំ និងទទួលយកបណ្តឹងឧទ្ធរណ៍ បើទោះបីតាមពិតថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានបំពេញ (១) លក្ខខណ្ឌក្នុងការដាក់សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ជូនក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត ក្នុងរយៈពេល ១០ថ្ងៃ ដែលជារយៈពេលកំណត់ដោយវិធានផ្ទៃក្នុង និងមុនពេលដាក់សំណើសុំបន្ថែមចំនួនទំព័រ និង/ឬបណ្តឹងឧទ្ធរណ៍ និង (២) មិនបានគោរពតាមចំនួនទំព័រ ដែលបានបញ្ជាក់ក្នុងមាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្ត ក៏ដោយ។

ភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ប្រាក់ គឹមសាន